## តើជនរំលោភបំពានផ្លូវភេទលើកុមារ ប្រតិបត្តិការយ៉ាងដូចម្តេច?

ជនបំពារបំពានប្រើប្រាស់វិធីសាស្ត្រច្រើនយ៉ាងដើម្បីបានចូលដល់ និង រំលោភបំពានលើកុមារ។

មនុស្សជាទូទៅច្រើនគិតថា ការរំលោភបំពានផ្លូវភេទលើកុមារកើតឡើង ដោយកម្រពីជនចម្លែក។ តែការពិត រឿងនេះកើតឡើងទូទៅ ដែលជនល្មើស និង/ឬ អ្នកកណ្តាល/មេអណ្តើកបានចំណាយពេលវេលាដើម្បីកសាងទំនាក់ទំនងជាមួយកុមារ (ជួនកាលទាក់ទងផ្ទាល់ជាមួយគ្រួសាររបស់ពួកគេ)។ ដំណើរការនេះគឺត្រូវបានស្គាល់ និងចាត់ទុកថាជាការទាក់ទាញតាមការបង្ហោះរូបភាពតាមអនឡាញ ដែលអាចប្រើប្រាស់វិធីសាស្ត្រជាច្រើនដំណាក់កាល។

**គោលដៅ**

ជនបំពារបំពានកត់សំគាល់កុមារដែលអាចរំលោភបំពានបាន។ ពួកគេតែងជ្រើសរើសកុមារងាយរងគ្រោះ។

**ការទុកចិត្ត**

ជនបំពារបំពានកសាងទំនុកចិត្តរបស់កុមារដោយការចែករំលែកផលប្រយោជន៍របស់ពួកគេ ឬផ្តល់អំណោយឲ្យកុមារ និងធ្វើឲ្យក្លាយទៅជាមិត្ត។

**ការសម្ងាត់**

ជនបំពារបំពានចាប់ផ្តើមមានការចរចារសម្ងាត់ជាមួយកុមារ ប្រើពាក្យសន្យា គំរាម ឬបង្ខិតបង្ខំកុមារឲ្យកុំឲ្យនិយាយ។

**បង្ហាញភាពទាក់ទាញ**

ជនបំពារបំពានបង្កើនឲ្យមានភាពទាក់ទាញខាងផ្លូវភេទនៃទំនាក់ទំនង។ ពួកគេបង្ហាញអំពីបញ្ហាការរួមភេទ និងបង្ហាញសម្ភារៈភេទដើម្បីឲ្យកុមារមានអារម្មណ៍រំភើប។

**ប្រព្រឹត្ត**

ជនបំពារបំពានសម្តែង (ប្រព្រឹត្ត) សកម្មភាពរួមភេទដ៏ស្រើបស្រាល។